Khmer

# MACI

## Massachusetts Access to Counsel Initiative

## គម្រោងទទួលសេវាប្រឹក្សារដ្ឋមាសាឈូសេត

គម្រោងទទួលសេវាប្រឹក្សារដ្ឋមាសាឈូសេ (MACI) ជាកម្មវិធីរួមគ្នា រវាងក្រុមចម្រុះ MIRA Coalition, CPCS, បណ្តាញអង្គការផ្នែកច្បាប់ទូទាំងរដ្ឋ។

ដោយកិច្ចសហការគ្នា យើងកសាងប្រព័ន្ធកណ្តាលមួយ សម្រាប់ទទួលសំណូមពរ និងបញ្ជូនបន្ត សម្រាប់អ្នករស់នៅរដ្ឋម៉ាសាឈូសេត ដែលកំពុងប្រឈមនឹងកិច្ចដំណើរការនីតិវិធីតុលាការអន្តោប្រវេសន៍។ តាមរយៈប្រព័ន្ធទូរស័ព្ទទទួលសំណូមពរតែមួយខ្សែ អ្នកដែលជាប់ឃុំ និងមិនជាប់ឃុំពីរដ្ឋមាសាឈូសេត នឹងអាចស្នើសុំជំនួយ និងភ្ជាប់ទៅអង្គការផ្តល់សេវាផ្នែកច្បាប់ដែលមានស្រាប់ សម្រាប់ជួយ បើត្រូវការ។

### តើកម្មវិធីដំណើរការយ៉ាងដូចម្តេច?

អ្នកដែលត្រូវការសេវា អាចទូរស័ព្ទទៅខ្សែទូរស័ព្ទទទួលសំណូមពរ និងបំពេញពាក្យសុំ។ យើងត្រូវការពេល ១៥-៣០នាទី អាស្រ័យលើស្ថានភាពជាក់ស្តែង។ ក្រោយបំពេញពាក្យសរួច យើងខ្ញុំនឹងបញ្ជូនបន្តទៅដៃគូផ្នែកច្បាប់ ដែលជាប់កិច្ចសន្យាជាមួយគ្នា ដើម្បីសុំជំនួយប្រឹក្សាយោបល់ (កំពុងរង់ចាំកម្លាំង)។

អ្នកហៅទូរស័ព្ទចូល អាចទុកឈ្មោះ និងលេខទូរស័ព្ទក្នុងសារជាសំឡេងក៏បាន បើទូរស័ព្ទជាប់រវល់។ ពួកយើងនឹងទូរស័ព្ទទៅវិញ ក្នុងរង្វង់មួយថ្ងៃនៃថ្ងៃធ្វើការ។ អ្នកជាប់ឃុំ គួរទុកឈ្មោះ និងលេខទូរស័ព្ទសមាជិកគ្រួសារ ដែលទុកចិត្ត។

### តើនរណាខ្លះ ត្រូវលក្ខខណ្ឌបានជំនួយនេះ?

អ្នកដែលជាប់ឃុំ និងមិនជាប់ឃុំ ពីរដ្ឋម៉ាសាឈូសេត ដែលឋិតក្នុងដំណាក់កាលចាប់បញ្ជូនចេញ និងដែលគ្រប់លក្ខខណ្ឌប្រាក់ចំណូលទាប នឹងលក្ខខណ្ឌតម្រូវផ្សេងទៀត។

### តើមានសេវាបកប្រែផ្ទាល់មាត់ដែរឬទេ?

**បាទ/ចាស!** អ្នកគ្រប់គ្រងទទួលសំណូមពរ គាត់ចេះនិយាយភាសាអេស្ប៉ាញ ហើយភាសាដទៃធ្វើតាមអ្នកបកប្រែ។

MIRA
Massachusetts Immigrant & Refugee Advocacy Coalition

សម្ព័ន្ធតស៊ូមតិសម្រាប់ជនអន្តោប្រវេសន៍ និងជនភៀសខ្លួននៅរដ្ឋម៉ាសាឈូសេដ (MIRA)

CPCS
Committee for Public Counsel Services
*Defending the People of Massachusetts*

គណៈកម្មាធិការសេវាប្រឹក្សាសាធារណៈ (CPCS)

**គម្រោង MACI ចាប់ទទួលពាក្យហើយ៖ (508) 505-4588**